**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តសៀមរាប**

សំណុំរឿងរដ្ឋប្បវេណីលេខ:២៦៥
ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៨
សាលក្រមលេខ: ១១ "ឃ"
ចុះថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩

# តា ង នា ម ប្រ ជា រា ស្ត្រ ខ្មែ រ

## សាលាដំបូងខេត្តសៀមរាប

-បានធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ និងប្រកាសសាលក្រម នៅបន្ទប់សវនាការលេខ: ០២ អា នៅថ្ងៃចន្ទ ១៤រោច ខែជេស្ឋ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៩ វេលាម៉ោងដប់ព្រឹក នៃសាលាដំបូងខេត្តសៀមរាប។

## ចៅក្រមជំនុំជម្រះ

លោកស្រី [redacted] ចៅក្រមសាលាដំបូងខេត្តសៀមរាប

## ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តសៀមរាប

លើសំណុំរឿងរដ្ឋប្បវេណីលេខ:២៦៥ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៨ ដែលមាន៖

**-ដើមចោទ:** ឈ្មោះ [redacted] **ចំរើន** ភេទស្រី អាយុ៣៦ឆ្នាំ មានទីលំនៅ [redacted]។

**-មេធាវីតំណាងដោយអាណត្តិដើមចោទ:** លោកស្រី [redacted] មានការិយាលនៅ [redacted]។

**-ចុងចម្លើយ:** ឈ្មោះ [redacted] **គឹមឆង** ភេទប្រុស អាយុ៣៨ឆ្នាំ មានទីលំនៅ [redacted]។

### ១-អង្គហេតុ និងចំណុចទទាន

**១-១-ដើមចោទប្តឹងសុំឲ្យតុលាការចេញសាលក្រមដូចខាងក្រោម៖**

-សុំលែងលះពីចុងចម្លើយឈ្មោះ [redacted] **គឹមឆង** ។

-សុំសិទ្ធិអំណាចមេបាលើកូនឈ្មោះ [redacted] **តាយសេង** ភេទប្រុស ថ្ងៃខែឆ្នាំកំណើត: ២៩.០២.២០០៨ និងឈ្មោះ [redacted] **មួយស៊ីង** ភេទស្រី ថ្ងៃខែឆ្នាំកំណើត: ០២.០៦.២០០៩។

-សុំទាមទារអាហារកិច្ចចិញ្ចឹមកូនទាំងពីរអ្នកខាងលើចំនួន១២០.០០០(មួយសែន ពីរសែន) រៀល ក្នុងមួយខែរហូតដល់នីតិភាព។

-ចំពោះប្រាក់ប្រដាប់ក្តីដើមចោទជាអ្នកទទួលបន្ទុក។

**១-២-ការពន្យល់ត្រួសៗពីអង្គហេតុ**

ដើមចោទ និងចុងចម្លើយឈ្មោះ [redacted] គឹមឆង បានអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ ដោយមានសេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០២ ដោយក្នុងការរួមរស់ជាមួយគ្នាមានកូនពីរនាក់ មួយឈ្មោះ [redacted] តាយសេង ភេទប្រុស ថ្ងៃខែឆ្នាំកំណើត: ២៩.០២.២០០៤ និងពីរឈ្មោះ [redacted] មួយស៊ាង ភេទស្រី ថ្ងៃខែឆ្នាំកំណើត: ០២.០៦.២០០៩។ ក្រោយមកចុងចម្លើយឈ្មោះ [redacted] គឹមឆង បានចាកចេញពីផ្ទះសម្បែងលែងរួមរស់ជាមួយដើមចោទអស់រយៈពេលប្រមាណប្រាំឆ្នាំ និងមាននារីថ្មីម្នាក់ទៀត។

**១-៣-សេចក្តីថ្លែងការណ៍របស់ភាគី**

**ដើមចោទបានធ្វើសេចក្តីថ្លែងការណ៍ថា:** ខ្លួន និងចុងចម្លើយឈ្មោះ [redacted] គឹមឆង បានរៀបអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ ដោយមានសេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០២ ដោយក្នុងការរួមរស់ជាមួយគ្នាមានកូនពីរនាក់ មួយឈ្មោះ [redacted] តាយសេង ភេទប្រុស ថ្ងៃខែឆ្នាំកំណើត: ២៩.០២.២០០៤ និងពីរឈ្មោះ [redacted] មួយស៊ាង ភេទស្រី ថ្ងៃខែឆ្នាំកំណើត: ០២.០៦.២០០៩។ ក្រោយមកចុងចម្លើយឈ្មោះ [redacted] គឹមឆង បានចាកចេញពីផ្ទះសម្បែងលែងរួមរស់ជាមួយខ្លួនអស់រយៈពេលប្រមាណប្រាំឆ្នាំ និងមាននារីថ្មីម្នាក់ទៀត ហេតុនេះទើបខ្លួនប្តឹងសុំទាមទារតាមកម្មវត្ថុខាងលើនេះ។

**ចុងចម្លើយបានធ្វើសេចក្តីថ្លែងការណ៍តបថា:** ខ្លួនឯកភាពតាមការទាមទារគ្រប់ចំណុចរបស់ភាគីដើមចោទ។

**១-៤-នីតិវិធីពិនិត្យភស្តុតាង**

-សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍លេខ: ១៣ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០២ ។

-សំបុត្របញ្ជាក់កំណើតលេខ: ៥៦ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ របស់ឈ្មោះ [redacted] **តាយសេង។**

-សំបុត្របញ្ជាក់កំណើតលេខ: ៨៣ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១២ របស់ឈ្មោះ [redacted] **មួយស៊ាង។**

**១-៥-ចំណុចវិវាទ គ្មាន។**

## ២-សំអាងហេតុ

ឆ្លងកាត់តាមនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ និងក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយៈ

២-១-ដើមចោទ និងចុងចម្លើយ មានចំណងអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ ដោយមានសេចក្តីចម្លងបុត្រអាពាហ៍ពិពាហ៍លេខ: ១៣ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០២។

២-២-តាមសំបុត្របញ្ជាក់កំណើតលេខ: ៤៦ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ របស់ឈ្មោះ [redacted] តាយសេង និងសំបុត្របញ្ជាក់កំណើតលេខ: ៨៣ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១២ របស់ឈ្មោះ [redacted] មួយស៊ាំង ពិតជាកូនបង្កើតរបស់ដើមចោទ និងចុងចម្លើយពិតប្រាកដមែន។

២-៣-តាមសេចក្តីថ្លែងការណ៍របស់គូភាគីឃើញថា: ភាគីទាំងពីរមានបំណងពិតប្រាកដក្នុងការរំលាយទំនាក់ទំនងអាពាហ៍ពិពាហ៍ ដោយភាគីចុងចម្លើយសុខចិត្តឯកភាពតាមការទាមទារគ្រប់ចំណុចរបស់ភាគីដើមចោទ ដោយយល់ព្រមលែងលះជាមួយដើមចោទ ,ប្រគល់សិទ្ធិអំណាចមេបាឲ្យដើមចោទជាម្តាយលើកូនឈ្មោះ [redacted] តាយសេង និងកូនឈ្មោះ [redacted] មួយស៊ាំង និងយល់ព្រមបង់អាហារកិច្ចចិញ្ចឹមកូនចំនួន៦០.០០០០ (ហុកសិបម៉ឺន) រៀល ក្នុងមួយខែ រហូតដល់នីតិភាព ដូចនេះផ្អែកតាមមាត្រា ៩៧៩, ១០៣៧ និងមាត្រា ១០៤០ នៃក្រមរដ្ឋប្បវេណី គប្បីតុលាការសម្រេចតាមឆន្ទះរបស់គូភាគី។ ប៉ុន្តែទុកសិទ្ធិឲ្យចុងចម្លើយដែលមិនបានគ្រប់គ្រងថែរក្សាកូនមានសិទ្ធិទៅសួរសុខទុក្ខកូនគ្រប់ពេលវេលាដែលសមស្រប ហើយដើមចោទជួយបង្កលក្ខណៈងាយស្រួលដល់ចុងចម្លើយ នៅពេលទៅសួរសុខទុក្ខកូន ស្របតាមមាត្រា ១០៤០ កថាខណ្ឌ១ នៃក្រមរដ្ឋប្បវេណី។

២-៤-ដោយភាគីដើមចោទយល់ព្រមទទួលបន្ទុកនូវប្រាក់ប្រដាប់ក្តី ដូចនេះគប្បីតុលាការសម្រេចតាមឆន្ទះរបស់ដើមចោទដោយស្របតាមមាត្រា៦៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## ៣-សេចក្តីសម្រេចបញ្ចប់

**៣-១-**ទទួលស្គាល់ការទាមទាររបស់ដើមចោទ ដោយឲ្យដើមចោទឈ្មោះ [redacted] ដាច់សមគ្គសង្វាសពីចុងចម្លើយឈ្មោះ [redacted] **គឹមឆង** ចាប់ពីពេលសាលក្រមនេះចូលស្ថាពរ។

**៣-២-**ឲ្យដើមចោទឈ្មោះ [redacted] **ចំរើន** ស្ថិតនៅក្នុងភាពមេម៉ាយចំនួន១២០(មួយរយម្ភៃ)ថ្ងៃ ស្របតាមមាត្រា៩៥០ នៃក្រមរដ្ឋប្បវេណី។

**៣-៣-**ប្រគល់សិទ្ធិអំណាចមេបាឲ្យដើមចោទឈ្មោះ [redacted] **ចំរើន** ជាអ្នកគ្រប់គ្រងលើកូនឈ្មោះ [redacted] **តាយសេង** ភេទប្រុស ថ្ងៃខែឆ្នាំកំណើត: ២៩.០២.២០០៥ និងឈ្មោះ [redacted] **មួយស៊ាំង** ភេទស្រី ថ្ងៃខែឆ្នាំកំណើត: ០២.០៦.២០០៩។ ប៉ុន្តែទុកសិទ្ធិឲ្យចុងចម្លើយដែលមិនបានគ្រប់គ្រងថែរក្សាកូនមានសិទ្ធិទៅសួរសុខទុក្ខកូនគ្រប់ពេលវេលា ដែលសមស្រប ហើយដើមចោទជួយបង្កលក្ខណៈងាយស្រួលដល់ចុងចម្លើយនៅពេលទៅសួរសុខទុក្ខកូន។

៣-៣-បង្គាប់ឲ្យចុងចម្លើយឈ្មោះ [redacted] **គឹមឆង** បង់អាហារកិច្ចចិញ្ចឹមកូនទាំងពីរអ្នក ខាងលើចំនួន៦០.០០០០ (ហុកសិបម៉ឺន) រៀល ក្នុងមួយខែ រហូតដល់នីតិភាព ។

៣-៤-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

**ចៅក្រមជំនុំជម្រះ**

**ហត្ថលេខា និងត្រា** [redacted]

---

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃសុក្រ ១១កើត ខែអាសាឍ ឆ្នាំកុរ ឯស័ក ព.ស ២៥៦៣

សៀមរាប ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩

**ក្រឡាបញ្ជី**

**បានឃើញ**

សៀមរាប ថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩

**ចៅក្រមជំនុំជម្រះ**

[redacted]